**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៥០១៥ សហវ.ឯកប

ថ្ងៃព្រហស្បតិ៍ ៤កើត ខែភទ្របទ ឆ្នាំ ច សំរឹទ្ធស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៨

**គោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍សម្រាប់ចំណាយពិសេសលើសម្ភារៈរៀននិងបង្រៀន និងដំណើរការសាលារៀនកុមារពិការភ្នែក និង គ ថ្លង់ នៃវិទ្យាល័យអប់រំពិសេសទាំងប្រាំ ។

**យោង៖** លិខិតលេខ ១៩៦៥ អយក.អពស ចុះថ្ងៃទី១១-០៤-២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ផ្អែកលើមូលដ្ឋានសំណើសុំអនុញ្ញាតជាគោលការណ៍សម្រាប់ចំណាយពិសេសលើសម្ភារៈរៀននិងបង្រៀន និងដំណើរការសាលារៀនកុមារពិការភ្នែក និង គ ថ្លង់ នៃវិទ្យាល័យអប់រំពិសេសទាំងប្រាំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យ និងឯកភាព ដូចខាងក្រោម ៖

១- ឯកភាពជាគោលការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា ចំណាយលើសម្ភារៈរៀន និងបង្រៀន អាហារហូបចុក ការស្នាក់នៅ សោហ៊ុយធ្វើដំណើរ និងដំណើរការសាលារៀនសម្រាប់សិស្សនៅវិទ្យាល័យអប់រំពិសេស ចំនួន ២០ ម៉ឺនរៀលក្នុងម្នាក់/មួយខែ ។ មុខសញ្ញាចំណាយនេះត្រូវកត់ត្រាចូលក្នុងអនុគណនី ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត)។

២- អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យលទ្ធភាពឥណទានថវិកាផ្ទៃក្នុង ឬថវិកាដែលសន្សំបានពីការចំណាយផ្សេងៗ និងធ្វើនិយ័តភាពឥណទានថវិកាសម្រាប់បម្រើដល់មុខសញ្ញាចំណាយនេះនៅឆ្នាំ២០១៨ ។ **ក្រសួងអប់រំ យុវជន និងកីឡា អាចស្នើសុំឥណទានថវិកាបន្ថែមសម្រាប់បង្គ្រប់ចំណាយមុខសញ្ញាចំណាយនេះ** មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច **ក្រោយពីបានធ្វើនិយ័តភាពឥណទានផ្ទៃក្នុងរួចរាល់ ហើយនៅតែមិនមានឥណទានថវិកាគ្រប់គ្រាន់ ។**



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៣- ដោយឡែក សម្រាប់ឆ្នាំ ២០១៩ និងឆ្នាំបន្តបន្ទាប់ ក្រសួងអប់រំ យុវជន និងកីឡាត្រូវគ្រោងចំណាយនេះទៅក្នុងផែនការប្រចាំឆ្នាំ ទៅក្នុងអនុគណនី ៦២០២៨ (ជំនួសសង្គមផ្សេងៗទៀត) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- ឯកសារ- កាលប្បវត្តិ